# អង្គការ អាយស៊ីស៊ី

# គោលនយោបាយ ប្រយុទ្ធប្រឆាំងការក្លែងបន្លំ និងអំពើពុករលួយ

**ប្រវត្តិឯកសារ**

| **អ្នកនិពន្ធ** | **កាលបរិច្ឆេទ** | **មូលហេតុនៃការផ្លាស់ប្តូរ** | **ជំនាន់** | **លក្ខណៈ** |
|---|---|---|---|---|
| ក្រុមគណនេយ្យ របស់អង្គការ អាយស៊ីស៊ី | ២០១០ | អនុវត្តនគោលនយោបាយ | ១.0 | អនុម័ត |
| អ្នកស្រី ស៊ូសាន ថារ៉ាត ម៉េតសេន និង អ្នកស្រី មាស សម្បត្តិ | ១១ កក្កដា ២០១៩ | គោលនយោបាយត្រូវបានធ្វើបច្ចុប្បន្នភាពដោយផ្អែកលើស្តង់ដារអប្បបរមារបស់អ្នកពាក់ព័ន្ធ | ១.១ | ពង្រាង |
| ក្រុមនាយកប្រតិបត្តិ | ២២ កក្កដា ២០១៩ | Review and approval<br>បានពិនិត្យឡើងវិញ នងអនុម័ត | ២.0 | អនុម័ត |

## ១- សេចក្តីផ្តើម

ព្រះអម្ចាស់ត្រាស់ហៅសហគមន៍ក្រុមជំនុំទូទាំងពិភពលោកដែលក្នុងនោះរួមទាំង អង្គកាអាយស៊ីស៊ីផងដែរដើម្បីប្រយុទ្ធប្រឆាំងប្រព័ន្ធអំណាចដែលអយុត្តិធម៌ ភាពមិនស្មើភាព ការរើសអើងដល់ជនក្រីក្រ និងជនបាត់បង់ឱកាស នឹងភាពអយុត្តិធម៌ផ្សេងៗទៀត ។ ព្រះអម្ចាស់ជាព្រះ ដែលនឹងប្រទានអំណាចដល់អ្នកដែលគ្មានអំណាច ហើយជួយរកយុត្តិធម៌សំរាប់អ្នកដែលត្រូវបានគេជិះជាន់ ។

នៅពេលដែលមានអំណាច គឺមានការទទួលខុសត្រូវ ពិសេសក្នុងការត្រួតត្រាផ្នែកធនធាន និង បរិស្ថាន ។ យើងទាំងអស់គ្នា មានកាតព្វកិច្ចដើម្បីថែរក្សា និងទទួលខុសត្រូវចំពោះគ្នាទៅវិញទៅមក និងចំពោះអ្វី ដែលព្រះបាន បង្កើត។ ដើម្បីទប់ស្កាត់ការក្លែងបន្លំ និងអំពើពុករលួយប្រកបដោយប្រសិទ្ធភាពនោះ អង្គការអាយស៊ីស៊ី ត្រូវអនុវត្តដោយមានការទទួលខុសត្រូវ និង ភាពសុចរិត ។

## ២- គោលនយោបាយអង្គការអោយស៊ីស៊ី

២.១ គោលនយោបាយជារួម:

- អង្គការអោយស៊ីស៊ីអនុវត្តគោលនយោបាយ ប្រយុទ្ធប្រឆាំងការក្លែងបន្លំ និង អំពើពុករលួយនេះដោយគ្មានការអត់អោន[1] ស្របតាមគោលនយោបាយដូចខាងក្រោម:
- អនុសញ្ញា និង គោលនយោបាយអន្តរជាតិ ដែលរាជរដ្ឋាភិបាលកម្ពុជាប្រកាន់ខ្ជាប់
- ច្បាប់ និង បទបញ្ញត្តិជាតិ ដែលកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា
- កិច្ចព្រមព្រៀងដៃគូរ/គម្រោង និង/ឬ អនុស្សរណៈយោគយល់ដែលបានចុះហត្ថលេខាជាមួយនឹងដៃគូរបស់អង្គការអោយស៊ីស៊ី
- គោលនយោបាយផ្ទៃក្នុង កិច្ចព្រមព្រៀង កិច្ចសន្យាជាដើម ដែលកំណត់ដោយក្រុមនាយកប្រតិបត្តិរបស់អង្គការអោយស៊ីស៊ី។

២.២ សេចក្តីថ្លែងការណ៍គោលនយោបាយ:

- ចំពោះរាល់ករណីប៉ុនប៉ង ការចោទប្រកាន់ ការសង្ស័យ ឬការរកឃើញការលួចក្លែងបន្លំ/អំពើពុករលួយ អង្គការអោយស៊ីស៊ី តម្រូវឱ្យមានការស៊ើបអង្កេតលើករណីនេះ
- ប្រសិនបើអត្តសញ្ញាណការក្លែងបន្លំ / អំពើពុករលួយត្រូវបានកំណត់អង្គការអោយស៊ីស៊ីនឹងចាត់វិធានការដូចខាងក្រោម:
    - អនុវត្តការពិន័យតាមនិតិវិធីរដ្ឋបាល ឬតាមកិច្ចសន្យា ឬ
    - ធ្វើការចោទប្រកាន់ដើម្បីកាត់ទោសដល់ជនល្មើស និង
    - ស្វែងរកសំណងដែលបានបាត់បង់ពីការក្លែងបន្លំ/អំពើពុករលួយ
- អង្គការអោយស៊ីស៊ី នឹងពង្រឹងយន្តការគ្រប់គ្រងផ្ទៃក្នុងនៃការក្លែងបន្លំ/អំពើពុករលួយក្នុងគោលបំណងដើម្បីទប់ស្កាត់ការកើតឡើងនាពេលអនាគត

## ៣- វិសាលភាពនៃគោលនយោបាយ

គោលនយោបាយនេះអនុវត្តចំពោះ នាយកប្រត្តិបតអង្គការ អ្នកគ្រប់គ្រង និងបុគ្គលិកប្រតិបត្តិការរបស់អង្គការអោយស៊ីស៊ីទាំងអស់ រួមបញ្ចូលទាំងបុគ្គលិកមិនពេញម៉ោង ពេញម៉ោង បុគ្គលិកទទួលបានប្រាក់បៀវត្សនិងបុគ្គលិកស្ម័គ្រចិត្ត។

ការហាមឃាត់ និងដែនកំណត់ដែលមានចែងនៅក្នុងគោលនយោបាយនេះ ត្រូវអនុវត្តចំពោះអ្នករាល់គ្នាដោយមិនគិតថាអ្នកទទួលផល គឺជាមន្ត្រីសាធារណៈ ឬ នរណាម្នាក់នៅក្នុងវិស័យឯកជន ឬ សង្គមស៊ីវិល ឡើយ ។

[1] គោលនយោបាយដែនកំណត់របស់នាយកប្រតិបត្តិអង្គការអោយស៊ីស៊ី ២.១០.១

## ៤- និយមន័យ

- **<u>ការក្លែងបន្លំ:</u>** ភាពមិនស្មោះត្រង់ក្នុងការទាញយកប្រយោជន៍ ឬការធ្វើឱ្យមានការបាត់បង់តាមរយៈការបោកបញ្ឆោត ឬតាមរយៈមធ្យោបាយផ្សេងទៀត[2]
- **<u>អំពើពុករលួយ:</u>** ការរំលោភបំពានទៅលើសិទ្ធិអំណាចដែលបានផ្តល់ឱ្យ ដើម្បីទាញយកផលប្រយោជន៍ផ្ទាល់ខ្លួន[3]
- **<u>ការមិនគោរពតាម:</u>** ការមិនគោរពតាមច្បាប់បទបញ្ញត្តិ ឬគោលការនៃកិច្ចសន្យាដែលបានធ្វើឡើងទោះបីដោយលក្ខណៈចៃដន្យ ឬដោយលក្ខណៈឱកាសនិយម។

<u>៤.១ ឧទាហរណ៍នៃការក្លែងបន្លំ:</u>

សកម្មភាពក្លែងបន្លំអាចកើតតាមរយៈការលើកទឹកចិត្ត ឱកាស ភាពសមហេតុផល ដែលអង្គការអោយស៊ីស៊ី បានកំណត់អត្តសញ្ញាណប៉ុន្តែមិនកំណត់ត្រឹម:

- ការលួច ឬការប្រើប្រាស់ទ្រព្យសម្បត្តិខុស
- ការលួច ឬការប្រើប្រាស់ថវិកាខុស
- ការក្លែងបន្លំវិក័យបត្រ
- ការមិនដឹកជញ្ជូនទំនិញ ឬសេវាកម្មតាមចំនួនកំណត់
- ការទូទាត់វិក័យបត្រពីរដង
- ការក្លែងបន្លំឯកសារ
- ការផ្តល់ពត៌មានលំអិតខុសឆ្គង ឬការលួចលុបពត៌មាន
- ការក្លែងបន្លំ និងទូរទាត់ចំពោះការធ្វើដំណើរ

<u>៤.២ ឧទាហរណ៍នៃអំពើពុករលួយ (សូមមើលឧបសម្ព័ន្ធ 1 ខាងក្រោមសម្រាប់និយមន័យ):</u>

អង្គការអោយស៊ីស៊ីកំណត់សកម្មភាពដូចខាងក្រោមនេះថាជាអំពើពុករលួយ
ប៉ុន្តែមិនកំណត់ត្រឹម:

- សំណូក
- ពេញចិត្តនិយម
- បក្សពួកនិយម
- ការកិបកេង

---

[2] ក្របខ័ណ្ឌត្រួតពិនិត្យការក្លែងបន្លំសហភាពអឺរ៉ុបឆ្នាំ 2017

[3] ការគ្រប់គ្រងការក្លែងបន្លំ DFAT និងផែនការប្រឆាំងអំពើពុករលួយ 2015

- ការស៊ុមគ្រលំ
- ការលាងលុយ
- ចំណាយដើម្បីពន្លឿន ឬក៏សំរបសំរួលការងារអ្វីមួយ
- ទំនាស់ផលប្រយោជន៍ (ស្ថានភាពដែលនរណាម្នាក់អាចទទួលបានផលប្រយោជន៍ផ្ទាល់ខ្លួន ពីទង្វើឬការសម្រេចចិត្តរបស់ពួកគេ)
- ការផ្តល់មូលនិធិខុសច្បាប់របស់គណបក្សនយោបាយ
- ការជំរិតទាមទារផលអ្វីមួយតាមរយៈពត៌មានសម្ងាត់
- ការផ្តល់អំណោយ (ប្រសិនបើខុសតាមគោលនយោបាយនៃការផ្តល់អំណោយរបស់អង្គការអោយស៊ីស៊ី)

**៥- យន្តការគ្រប់គ្រងសកម្មភាពការក្លែងបន្លំ/អំពើពុករលួយ**

<u>៥.១ ការបង្ការៈ</u>

អង្គការអោយស៊ីស៊ី នឹងចាត់វិធានការដូចខាងក្រោមចំពោះការការពារកាក្លែងបន្លំ / អំពើពុករលួយ ប៉ុន្តែមិនកំណត់ត្រឹមៈ

- ការវាយតម្លៃហានិភ័យ ដើម្បីការការពារ
- ការបណ្តុះបណ្តាល និងគោលការណ៍ណែនាំ
- ការបង្កើតការការពារចូលទៅក្នុងការរៀបចំគម្រោងដោយផ្អែកទៅលើការវាយតម្លៃហានិភ័យ
- រាល់បុគ្គលិកអង្គការអោយស៊ីស៊ីទាំងអស់ យល់ពីអត្ថប្រយោជន៍នៃការគោរពតាមគោលការណ៍នេះ និងផលលំបាក់ពីការមិនគោរពតាម។

<u>៥.២ ការស៊ើបអង្កេតៈ</u>

អង្គការអោយស៊ីស៊ី នឹងប្រើយន្តការគ្រប់គ្រងដូចខាងក្រោម ចំពោះការរកឃើញការក្លែងបន្លំ/អំពើពុករលួយ ប៉ុន្តែមិនកំណត់ត្រឹមៈ

- រាយការណ៍ពីការក្លែងបន្លំ
- អ្នករាយការណ៏សម្ងាត់ (សូមមើលឧបសម្ព័ន្ធ 2 ខាងក្រោម)
- សវនកម្មផ្ទៃក្នុង និងខាងក្រៅ
- ត្រួតពិនិត្យមើលដល់ទីកន្លែង និងត្រួតពិនិត្យបញ្ជីដោយមិនប្រាប់មុន
- ពិនិត្យមើលវិក័យប័ត្រទាំងអស់ម្តងទៀត
- ការអង្កេតមើល។

៥.៣ ការកែតម្រូវ:

អង្គការអោយស៊ីស៊ី នឹងប្រើយន្តការខាងក្នុងចំពោះការក្លែងបន្លំ/អំពើពុករលួយ:
ប៉ុន្តែមិនកំណត់ត្រឹម:

- ការទទួលសំណងត្រលប់មកវិញ
- ការដាក់ពិន័យតាមនិតិវិធីរដ្ឋបាល ឬការដាក់ទណ្ឌកម្មផ្អែកតាមកិច្ចសន្យា។

៥.៤ នីតិវិធីនៃការដាក់ទណ្ឌកម្ម:

អង្គការអោយស៊ីស៊ី នឹងប្រើយន្តការដាក់ទណ្ឌកម្មដូចខាងក្រោមដែលបានប្រឆាំងនឹងការក្លែងបន្លំ / អំពើពុករលួយ:

- ការកាត់ទោសតាមច្បាប់ព្រហ្មទណ្ឌ
- ការកាត់ទោសតាមច្បាប់រដ្ឋប្បវេណី
- ការដាក់ទណ្ឌកម្មផ្សេងៗទៀត តាមកម្រិតនៃការមិនគោរពតាម (ឧ.ពិន័យ ការប្រមានដោយពាក្យសំដី/ការប្រមានដោយលាយលក្ខ័អក្សរ ការបណ្តេញចេញ )។

**៦- រាយការណ៍អំពីការក្លែងបន្លំ/អំពើពុករលួយ**

៦.១ កាតព្វកិច្ចនៃការរាយការណ៍:

បុគ្គលិករបស់អង្គការអោយស៊ីស៊ី (ដូចដែលបានកំណត់នៅក្នុង "វិសាលភាព" ខាងលើ) មានកាតព្វកិច្ចក្នុងការរាយការណ៍ពីការរំលោភបំពានលើគោលនយោបាយនេះ ។

រាល់សកម្មភាពដែលសង្ស័យ ត្រូវតែរាយការណ៍ទៅកាន់សមាជិកណាម្នាក់ក្នុងចំណោមសមាជិកនាយកប្រតិបត្តិ ។

បុគ្គលិកណាដែលខកខានមិនបានរាយការណ៍សកម្មភាពសង្ស័យ ដែលបុគ្គលិកម្នាក់នោះបានដឹង ឬ សង្ស័យ អាចនិងទទួលបានការដាក់ពិន័យចំពោះបុគ្គលិកនោះដោយសារការមិនបានរាយការណ៍ ។ អង្គការអោយស៊ីស៊ី នឹងមិនអនុញ្ញាតឱ្យមានសកម្មភាពសងសឹក ឬគំគួនណាមួយប្រឆាំង នឹងបុគ្គលិកណាដែលរាយការណ៍ ពីសេចក្តីសង្ស័យលើគោលនយោបាយនេះឡើយ ។

៦.២ ជំហាននៃការរាយការណ៍:

**ជំហានទី១** រាយការណ៍រាល់សកម្មភាពដូចជាការប៉ងធ្វើអ្វីមួយ ចោទប្រកាន់ សង្ស័យ ឬបានរកឃើញពីការក្លែងបន្លំ/អំពើពុករលួយនៅក្នុងអង្គការអោយស៊ីស៊ី ។ ការសង្ស័យអាចរាយការណ៍បានដោយពុំចាំបាច់មាន
ភស្តុតាងជាមុនទេ ។

**ជំហានទី២** សូមធ្វើកំណត់ចំណាំរាល់សកម្មភាពដែលគួរឱ្យសង្ស័យណាដែលអាចធ្វើជាភស្តុតាង ឬឮ ហើយរក្សាវាទុកជាឯកសារស្របច្បាប់ប្រសិនបើអាចធ្វើបាន។

**ជំហានទី៣** រក្សាការសម្ងាត់ ដោយបូករួមទាំងចំនួនអ្នកទទួលផល "ចម្លង" នៅក្នុងអ៊ីមែល។

## ៧- នីតិវិធីនៃការស៊ើបអង្កេត

នាយកអង្គការជាអ្នកទទួលខុសត្រូវក្នុងការចាប់ផ្តើមការស៊ើបអង្កេតភ្លាមៗដែលរួមមាន:

- រាយការណ៍រាល់ការប៉ុនប៉ង, ការចោទប្រកាន់, ការសង្ស័យ ឬការក្លែងបន្លំ/អំពើពុករលួយទៅដល់អ្នកពាក់ពន្ធ័នៅក្នុងក្របខណ្ឌពេលវេលារបស់ពួកគេ ។
- បង្កើតគណៈកម្មាធិការស៊ើបអង្កេត និងរៀបរាប់អំពីតួនាទី និងការទទួលខុសត្រូវរបស់ពួកគេចំពោះករណីជាក់លាក់ដែលបានកើតឡើងដោយរួមទាំងកំណត់ពេលវេលាអង្កេតច្បាស់លាស់
- ធានាថាការស៊ើបអង្កេតត្រូវបានអនុវត្តដូចដែលបានកំណត ហើយត្រូវធ្វើបច្ចុប្បន្នភាពអោយអ្នកដែលពាក់ពន្ធ័ទាំងអស់
- អនុម័តរបាយការណ៍ស៊ើបអង្កេតចុងក្រោយ និង ចែករំលែកវាជាមួយអ្នកដែលពាក់ព័ន្ធ
- ចាត់វិធានការទៅតាមអ្វីដែលបានរកឃើញក្នុងរបាយការណ៍ស៊ើបអង្កេត ដោយផ្អែកលើគោលនយោបាយនេះ

## ៨- គណនេយ្យភាពផ្ទាល់ខ្លួន

ការពិន័យ និងការចំណាយផ្សេងទៀតជាបន្ទុករបស់បុគ្គលិកដែលបានធ្វើខុសទៅនិងគោលនយោបាយនេះ នឹងមិនត្រូវបានទូទាត់ដោយអង្គការអោយស៊ីស៊ីទេ ប៉ុន្តែត្រូវបង់ដោយបុគ្គលិកដែលបានប្រព្រឹត្តិបទល្មើសនោះវិញ។

រាល់ការរំលោភបំពាននៃគោលនយោបាយនេះអាចបណ្តាលឱ្យទទួលលទ្ធិផលជាពិន័យ និងអាចរហូតដល់ការបញ្ចប់កិច្ចសន្យារបស់ពួកគេជាមួយអង្គការអោយស៊ីស៊ី ។

## ៩- ការកែប្រែគោលនយោបាយ និងការបណ្តុះបណ្តាលផ្ទៃក្នុង

គោលនយោបាយនេះនឹងត្រូវបានពិនិត្យឡើងវិញយ៉ាងហោចណាស់ ជារៀងរាល់ឆ្នាំទីបី ។ ប្រសិនបើចាំបាច់គោលនយោបាយនឹងត្រូវធ្វើបច្ចុប្បន្នភាពដោយផ្អែកលើតម្រូវការស្តង់ដាខាងក្នុងនិងខាងក្រៅ ដើម្បីរក្សាគោលជំហរដោយគ្មានការអត់អោនចំពោះការក្លែងបន្លំ និងអំពើពុករលួយ ។

គោលនយោបាយនេះនឹងត្រូវបានពិនិត្យឡើងវិញជាមួយបុគ្គលិកហិរញ្ញវត្ថុរបស់អង្គការអោយស៊ីស៊ី ទាំងអស់រៀងរាល់ឆ្នាំ ហើយការបណ្តុះបណ្តាលផ្ទៃក្នុងនឹងត្រូវបានអនុវត្តសម្រាប់បុគ្គលិកអាយស៊ីស៊ី ទាំងអស់រៀងរាល់ពីរឆ្នាំម្តង។

**ឧបសម្ព័ន្ធ ១**

**សំណូក:** គឺការផ្តល់ជូន សន្យា ផ្តល់ឱ្យ ទទួលយក ឬ ការសុំគុណសម្បត្តិជាការលើកទឹកចិត្តចំពោះសកម្មភាពដែលខុសច្បាប់គ្មានសីលធម៌ឬការបំពានលើទំនុកចិត្ត ។ ការលើកទឹកចិត្តមានទំរង់ដូចជាអំណោយ ប្រាក់កម្ចី ថ្លៃឈ្នួលរង្វាន់ ឬគុណសម្បត្តិផ្សេងៗទៀត (ពន្ធ សេវាកម្ម ការបរិច្ចាគអំណោយផ្សេងទៀត ។ ល។ ) ។

**ពេញចិត្តនិយម:** ទង្វើដែលមានភាពលំអៀងទៅលើនរណាម្នាក់ដោយមិនយកចិត្តទុកដាក់ចំពោះអ្នកផ្សេងទៀត ។

**បក្សពួកនិយម:** ជាទម្រង់មូលដ្ឋាននៃការពេញចិត្តនិយម ហើយដោយផ្អែកទៅលើការស្គាល់គ្នា ទំនាក់ទំនងជិតស្និទ្ធបានផ្តល់ការងារ ឬការអនុគ្រោះទៅអោយសមាជិកគ្រួសាររបស់មិត្តភក្ត្រ ទោះបីមិនមានសត្ថភាពគ្រប់គ្រាន់នឹងទទួលបានការងារក៏ដោយ ។

**ការកិបកេង:** នៅពេលដែលបុគ្គលម្នាក់ដែលមានតួនាទី នៅក្នុងស្ថាប័នគ្រឹះស្ថាន ឬក្រុមហ៊ុន ដែលមានភាពមិនស្មោះត្រង់ នឹងបានប្រើប្រាស់ប្រាក់ (ថវិកា) និងទំនិញដែលស្ថិតក្នុងការទទួលខុសត្រូវរបស់ខ្លួនដើម្បីបង្កើនផលប្រយោជន៏ផ្ទាល់ខ្លួន ឬសកម្មភាពផ្សេងៗទៀត។

**ការស៊ុមក្រលំ:** ការព្រមព្រៀងដោយសម្ងាត់រវាងភាគីនានា ដើម្បីផ្សំគំនិតបោកបញ្ឆោត ឬការលួចបន្លំដែលមានគោលដៅក្នុងការរកលុយខុសច្បាប់។ ភាគីដែលជាប់ទាក់ទងជាញឹកញាប់ត្រូវបានគេសំដៅថាជា "ក្រុមកាតែលគឺក្រុមមនុស្សដែលយល់ព្រមលក់ទំនិញអ្វីមួយនៅក្នុងតម្លៃលាក់បាំងពិសេសដើម្បីជាសវាងការប្រកួតប្រជែង ទង្វើនេះនាំអោយគេបង្កើនប្រាក់ចំណេញច្រើន។

**ការលាងលុយកខ្វក់:** វាជាឧក្រិដ្ឋកម្មនៃការសារាចរណ៏សាច់ប្រាក់ដោយខុសច្បាប់ តាមរយៈធនាគារនិ ងអាជីវកម្មផ្សេងៗទៀត ដើម្បីធ្វើឱ្យវាមើលទៅដូចជាប្រាក់ត្រូវបានគេទទួលបានស្របច្បាប់។

**ការទូទាត់សម្របសម្រួល:** ការចំណាយតិចតួចក្រៅផ្លូវការដែលត្រូវបានធ្វើឡើងដើម្បីពន្លឿន ឬធានាដល់ការផ្តល់សេវាកម្មរបស់រដ្ឋាភិបាល ដែលសេវាកម្មនេះគួតែបំពេញដោយរដ្ឋាភិបាលដោយមិនបាច់ចំណាយប្រាក់ជូន។

**ទំនាស់ផលប្រយោជន៍:** (ស្ថានភាពដែលនរណាម្នាក់អាចទទួលបានផលប្រយោជន៏ផ្ទាល់ខ្លួន ពីទង្វើឬការសម្រេចចិត្តរបស់ពួកគេ) ទំនាស់ផលប្រយោជន៍កើតមានឡើងនៅពេលដែលប្រើទំនាក់ទំនងផ្ទាល់ខ្លួន ដើម្បីមានឥទ្ធិពលលើការសម្រេចចិត្តរបស់មនុស្សម្នាក់។ ទង្វើនេះបង្ហាញពីផលប្រយោជន៏ផ្ទាល់ខ្លួនជាមួយផលប្រយោជរបស់អង្គការ

**ការផ្តល់មូលនិធិខុសច្បាប់របស់គណបក្សនយោបាយ:** ការគាំទ្រហិរញ្ញវត្ថុសម្រាប់គណបក្សនយោបាយដោយបុគ្គលឬអង្គការ / ក្រុមហ៊ុនដើម្បីទទួលបានមានប្រយោជន៍ពីការសំរេចចិត្តផ្នែកនយោបាយនោះ (ឧ. ការធ្វើវិសោធនកម្មច្បាប់ដើម្បីសម្របសម្រួលអាជីវកម្មអ្នកគាំទ្រ) ។

**ការជំរិតទាមទារផលអ្វីមួយតាមរយៈពត៌មានសម្ងាត់:** ទាមទារប្រាក់ ឬអត្ថប្រយោជន៍ផ្សេងទៀតពីបុគ្គលម្នាក់ដោយមានលក្ខខណ្ឌមិនបង្ហាញពីអាថ៌កំបាំង ឬព័ត៌មានដែលនាំអោយមានគ្រោះថ្នាក់ដល់បុគ្គលនោះ។

**ការអោយអំណោយ:** សូមមើលគោលនយោបាយនៃការអោយអំណោយរបស់អង្គការអោយស៊ីស៊ី ។

**ឧបសម្ព័ន្ធ ២**

អ្នករាយការណ៍សម្ងាត់
អង្គការអោយស៊ីស៊ីបានកំណត់និយមន័យ "អ្នករាយការណ៍សម្ងាត់" ថាជាបុគ្គលិកអង្គការអោយស៊ីស៊ីដែលធ្វើសេចក្តីរាយការណ៍ដោយមានបំណងល្អ[4] អំពីការខុសឆ្គង រួមទាំងការសង្ស័យថាការក្លែងបន្លំ/អំពើពុករលួយការប្រើប្រាស់ធនធានមិនត្រឹមត្រូវ ការមិនយកចិត្តទុកដាក់លើភារកិច្ច ឬហានិភ័យដល់សុខភាព
និងសុវត្ថិភាព។

របាយការណ៍អាចធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ ហើយគួរតែបញ្ចូលព័ត៌មានលំអិតតាមដែលអាចធ្វើទៅបាន ហើយប្រសិនអាចសូមភ្ជាប់ភស្តុតាងជាមួយ។ ពាក្យបណ្តឹងអនាមិកអាចទទួលយកបាន។ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយក្រុមការងារនាយកប្រត្តិបត្តិរបស់អង្គការអោយស៊ីស៊ី អាចដឹងពីអ្នកដែលជាអ្នកចោទប្រកាន់។ ក្រុមនាយកប្រតិបត្តិរបស់អង្គការអោយស៊ីស៊ី នឹងផ្តល់ការគោរពដល់អ្នករាយការណ៍សម្ងាត់ក្នុងករណីដែលអាចធ្វើទៅបាន។

អង្គការអោយស៊ីស៊ី នឹងខិតខំប្រឹងប្រែងដើម្បីការពារអ្នកដែលរាយការណ៍សម្ងាត់ ដែលមានបំណងល្អពីការរាយការណ៍នេះ។ ដោយរួមបញ្ចូលទាំងការការពារពីការរើសអើង ការយាយី និងជនរងគ្រោះ។ ទោះជាយ៉ាងណាក៏ដោយសកម្មភាពពិន័យនឹងត្រូវបានធ្វើឡើងប្រឆាំងនឹងបុគ្គលិកដែលត្រូវបានរកឃើញថាបានធ្វើរបាយការណ៍មិនពិតឬមិនស្មោះត្រង់ដែលអាចប៉ះពាល់ដល់អ្នកដទៃ។ ការរាយការណ៍បែបនេះអាចបណ្តាលឱ្យ មានការបណ្តេញចេញពីការងារ។

[4] មានជំនឿល្អ: មិនមានចេតនាធ្វើបាបឬសងសឹកអ្នកដទៃឡើយ។